# កិច្ចព្រមព្រៀង

រវាង

## មន្ទីរពេទ្យ កាល់ម៉ែត

និង

## អង្គការ កម្ពុជាស្រឡាញ់

# ខ្លឹមសារជាមូលដ្ឋាន

ឯកសារយោង: ឯកសារយោងនៃ កិច្ចព្រមព្រៀងរវាង មន្ទីរពេទ្យកាល់ម៉ែត និងអង្គការកម្ពុជាត្រាស្ត គឺអនុស្សរណៈ រវាងក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា (ស.ក.ប.យ.) និងអង្គការកម្ពុជាត្រាស្ត (CTRP) ដែលបានចុះហត្ថលេខា នៅថ្ងៃទី ១៣ ខែ ធ្នូ ១៩៩៩ ។

អង្គការកម្ពុជាត្រាស្ត គឺជាអង្គការមនុស្សធម៌ក្រៅរដ្ឋាភិបាល (ចុះបញ្ជីសប្បុរសនៅប្រទេសអង់គ្លេសលេខ ១០៣៤៧៦) បានផ្តល់ការគាំពារផ្នែកជើងដៃ សិប្បនិម្មិត និង រណប. សេវាព្យាបាលដោយចលនា និង សេវាជួយជនពិការតាមសហគមន៍នៅទីក្រុងភ្នំពេញ និងខេត្តកណ្តាល ដោយអនុលោមតាមអនុស្សរណៈ រវាង ស.ក.ប.យ និងអង្គការកម្ពុជាត្រាស្ត ដូចបានបញ្ជាក់ខាងលើ ។ អនុស្សរណៈក៏បានបញ្ជាក់ផងដែរ នូវកម្មវិធីបណ្តុះបណ្តាលអ្នកបច្ចេកទេស ផលិតជើង-ដៃសិប្បនិម្មិត និង រណប ជាជនជាតិកម្ពុជា និងមកពីបណ្តាប្រទេសមួយចំនួន។ សេវាកម្មនេះត្រូវបានផ្តល់ដោយ អង្គការកម្ពុជាត្រាស្ត ក្រោម ជំពោះកម្មវិធីគឺ " សាលាបច្ចេកទេសផលិតជើង-ដៃសិប្បនិម្មិត និង រណប កម្ពុជា " ហៅ កាត់ថា CSPO ដែលមានទីតាំងនៅក្នុងបរិវេណនៃមន្ទីរពេទ្យកាល់ម៉ែត។ អង្គការ កម្ពុជាត្រាស្តមានបំណងបន្តនូវសេវាកម្មនេះ នៅក្នុងទីតាំងមន្ទីរពេទ្យកាល់ម៉ែត្រ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ សំរាប់រយៈពេល៥ឆ្នាំទៀត គិតចាប់តាំងពីថ្ងៃចុះហត្ថលេខា លើកិច្ច ព្រមព្រៀងនេះ។

## ជំពូក ១

## ការទទួលខុសត្រូវរបស់ មន្ទីរពេទ្យកាល់ម៉ែត

ប្រការ ១ : ផ្តល់នូវទីតាំងសមស្របសំរាប់អាគារ ដើម្បីផ្តល់ការគាំពារផ្នែកជើង-ដៃសិប្បនិម្មិត និង រណប. ផ្នែកសេវាព្យាបាលដោយចលនា និង កម្មវិធីជួយជនពិការតាមសហគមន៍ នៅក្នុងបរិវេណនៃមន្ទីរពេទ្យកាល់ម៉ែត មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ។ សេវាផ្សេងទៀត ដោយរួមបញ្ចូលទាំងកម្មវិធីបណ្តុះបណ្តាលអ្នកបច្ចេកទេស ផលិតជើង-ដៃ

សិប្បនិម្មិត និង រណប។ កម្មវិធីនេះឈ្មោះថា សាលាបច្ចេកទេស ផលិតជើង-ដៃ សិប្បនិម្មិត និង រណប កម្ពុជា (CSPO) ។

ប្រការទី ២ : ផ្តល់នូវលទ្ធភាពសមស្របសំរាប់ប្រពន្ធ័ បង្ហូរទឹកកខ្វក់ ចេញពី អាគារដែលមានទីតាំងដូចខាងលើ ។

ប្រការទី ៣ : ផ្តល់នូវលទ្ធភាពចេញ - ចូលសមស្របសំរាប់រថយន្ត និងទីតាំងចតរថយន្ត នៅក្បែរ អាគារ ។

ប្រការទី ៤: អនុញ្ញាតិអោយនិស្សិតស្នាក់នៅក្នុង អន្តេវាសិកដ្ឋានចំនួន ៣៦ នាក់ ។

## ជំពូកទី២

### ការទទួលខុសត្រូវរបស់ អង្គការកម្ពុជាត្រាស្ត

ប្រការទី ៥ : អនុវត្ត តាមវិន័យ និង បទបញ្ជាផ្សេងៗ របស់មន្ទីរពេទ្យកាល់ម៉ែត។

ប្រការទី ៦ : ផ្តល់នូវការថែទាំ ជាទៀងទាត់ និង ជួសជុលអាគារ ។

ប្រការទី ៧ : ផ្តល់នូវលទ្ធភាពសមស្របសំរាប់ ការភ្ជាប់នូវប្រពន្ធ័បង្ហូរទឹកកខ្វក់ ជាមួយមន្ទីរពេទ្យកាល់ម៉ែត នៅកន្លែងណាដែលអាចធ្វើបាន ។

ប្រការទី ៨ : ស្នើសុំការឯកភាពពី មន្ទីរពេទ្យកាល់ម៉ែតជាមុន មុននឹងធ្វើការផ្លាស់ប្តូរទ្រង់ទ្រាយសំណង់ណាដែលមាន លក្ខណៈជាសំណង់ខាងក្រៅអាគារ ។

ប្រការទី ៩ : ទទួលខុសត្រូវ ក្នុងការបង់ថ្លៃប្រើប្រាស់ ចរន្តអគ្គីសនី និង ទឹកស្អាត ដែលបំរើ អោយកម្មវិធីខាងលើ ។

## ជំពូកទី ៣

### បទបញ្ជា

ប្រការទី១០ : មន្ទីរពេទ្យកាល់ម៉ែត នឹងមិនមានការទទួលខុសត្រូវចំពោះ រាល់ការខូចខាតទាំងឡាយណា ដែលបង្កឡើងដោយសកម្មភាពរបស់ អង្គការកម្ពុជាត្រាស្ត ។

ប្រការទី១១ : រាល់វិសោធនកម្ម ជាលាយលក្ខណ៍អក្សរសំរាប់កិច្ចព្រមព្រៀងនេះ នឹង ត្រូវបានដាក់បញ្ចូល លុះត្រាតែមានការឯកភាព ពីភាគីទាំងពីរ ក្រោយពីបានពិគ្រោះយ៉ាងម៉ត់ចត់ ។

ប្រការទី ១២ :  កម្មវិធីដែលបានចែងនៅក្នុងខ្លឹមសារនៃកិច្ចព្រមព្រៀង នឹងមានសុពលភាពរយៈពេល ៥ ឆ្នាំ។ មន្ទីរពេទ្យកាល់ម៉ែត និងអង្គការ កម្ពុជាក្រាស្ត នឹង ស៊ើរើពិនិត្យមើលឡើងវិញរយៈពេល ៣ ខែមុនកិច្ចព្រមព្រៀងត្រូវអស់សុពលភាព និងត្រូវសំរេចថាតើកិច្ចព្រមព្រៀងគួរត្រូវបន្ត ឬពន្យាពេល ។

ប្រការទី ១៣ :  កិច្ចព្រមព្រៀងនេះ នឹង ត្រូវចូលជាធរមានចាប់ពីថ្ងៃដែលបានចុះហត្ថលេខា ។

ប្រការទី ១៤ :  កិច្ចព្រមព្រៀងនេះ នឹងត្រូវរក្សាទុកដោយមន្ទីរពេទ្យកាល់ម៉ែត និងអង្គការកម្ពុជាក្រាស្ត ។

បានចុះហត្ថលេខានៅភ្នំពេញ ថ្ងៃទី ....26....... ខែ ....កក្កដា ឆ្នាំ ២០០១ ច្បាប់ដើមនៃកិច្ចព្រមព្រៀង ត្រូវបានធ្វើជា ២ ច្បាប់ ទាំងភាសាខ្មែរ និងភាសាអង់គ្លេស ដែលមានតំលៃដូចគ្នា ។

ហត្ថលេខី

| | |
|---|---|
| តំណាងអង្គការ កម្ពុជាក្រាស្ត | តំណាងមន្ទីរពេទ្យ កាល់ម៉ែត |
| Kathleen Biggs | លោកសាស្ត្រាចារ្យ |
| នាយក អង្គការកម្ពុជាក្រាស្ត | វេជ្ជបណ្ឌិត ហេង តៃគ្រី |
| | នាយកមន្ទីរពេទ្យកាល់ម៉ែត |